# របាយការណ៍ប្រចាំឆ្នាំ២០១៣

នៅក្នុងឆ្នាំ ២០១៣ ប្រទេសកម្ពុជា សម្រេចបានអត្រាកំណើនសេដ្ឋកិច្ចគួរឲ្យមោទនៈក្នុងអត្រា ៧% ដូចដែលបានព្យាករណ៍ ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោក និង ៧.២% ដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ។ លទ្ធផលនេះពីការកើនឡើងនៃការវិនិយោគនៅក្នុងប្រទេស ដូចជាវិស័យសំណង់និងវិស័យទេសចរណ៍ ។ ជាមួយនឹង ស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរយៈពេល១០ឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបានក្នុងរង្វង់ ៤% ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ទន្ទឹមនឹងការប្រមូលចំណូលរបស់រដ្ឋាភិបាលកើនឡើង ឱនភាពថវិកាជាតិថយចុះនិងបរិយាកាសនៃការវិនិយោគក្នុងប្រទេសកម្ពុជាមានការទាក់ទាញ ដូចនេះអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បាន ព្យាករណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជា នឹងរក្សាបានអត្រាកំណើនល្អប្រសើរក្នុងរយៈពេលមធ្យម ។ នៅក្នុងសុន្ទរកថា ដោយលោកស្រី Christine Lagarde ប្រធានអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ នៅសាលាភូមិន្ទរដ្ឋបាលនៅក្នុងអំឡុងពេលទស្សនកិច្ចរបស់លោកស្រី កាលពីដើមខែធ្នូឆ្នាំ ២០១៣ បានមានប្រសាសន៍ទាក់ទងនឹងអត្រាណើនសេដ្ឋកិច្ច និងអត្រាអតិផរណា របស់ប្រទេសកម្ពុជាថា ជាអត្រាមួយដែលប្រទេសភាគច្រើនក្នុងពិភពលោកចង់បាន ។

ធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលយ៉ាងគាប់ប្រសើរ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ ជាមួយនឹងអត្រាអតិផរណា ត្រឹម ៤% ក្នុងឆ្នាំ ២០១៣ ដែលជាអត្រាមួយទាបបំផុតនៅក្នុងតំបន់ព្រមទាំងរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ក្នុងចន្លោះពី ៤០៩២,៧ ទៅ ៤១០១,៧ ក្នុងរយៈពេល ១០ឆ្នាំ ។ ស្ថិរភាពនិងការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុបានបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុដល់អ្នកដែលមានចំណូលទាប សហគ្រាសធុនតូច និងសាជីវកម្ម ក្នុងវិស័យផលិតកម្ម បានរួមចំណែកក្នុងការជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចក្នុងប្រទេស។

ទុនបម្រុងអន្តរជាតិរបស់ប្រទេសកម្ពុជា ដែលគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជាបានកើនឡើង ពីចំនួនប្រហែល ៣៧៨ លានដុល្លារអាមេរិកទៅដល់៤.១០០លានដុល្លារអាមេរិក ក្នុងរយៈពេល១៥ឆ្នាំ កន្លងមកនេះ ។ ក្នុងពេលបច្ចុប្បន្ននេះ បរិមាណទុនបម្រុងអន្តរជាតិអាចទូទាត់ការនាំចូលសម្រាប់ រយៈពេល ៤ ខែ និងបានឈានដល់កម្រិតមួយខ្ពស់នៃធនធានរបស់ប្រទេសកម្ពុជា ដែលមិនធ្លាប់ មានពីមុនមក ។

នៅក្នុងឆ្នាំ ២០១៤ និងឆ្នាំខាងមុខ ធនាគារជាតិនៃកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយរបស់ខ្លួន យ៉ាងប្រុងប្រយ័ត្នដើម្បីសម្រេចបានបេសកម្មរបស់ខ្លួន និងរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីភាពចុំចំរើនរបស់ប្រទេសកម្ពុជា។

***Annual Report 2013 Released***

In 2013, Cambodia's economy achieved commendable result with a GDP growth of 7% as forecast by the IMF and the World Bank and 7.2% by ADB. Such a performance comes from an increase in investments in the country, particularly in construction and tourism sectors. With stable exchange rate based on sound macro-fundamentals for the past 10 years, inflation rate within a manageable level of 4 % annually for the last 5 years, consistent improvement in government revenue collection, decreasing budget deficit and attractiveness of Cambodia's investment environment, IMF projects Cambodia's growth to maintain its momentum in the medium term. During Ms Christine Lagarde's, Managing Director of the IMF, visit in early December 2013, in her speech at Royal School of Administration (ERA) she referred to Cambodia's growth and inflation figures as "figures envied by many countries in the world."

The National Bank of Cambodia in particular, has achieved satisfactory result in fulfilling its mission as Cambodia's central bank, in maintaining price stability with 2013 inflation rate standing at around 4%, one of the lowest in the region and achieving a stable average exchange rate within a range of 4092,7 – 4101,7 riel to a dollar for the past 10 years. In addition, the financial system remains stable and continues to develop, providing financing need to low income people, SMEs and corporations in the productive sectors of the economy and ultimately contributing to Cambodia's economic growth.

Cambodia's foreign reserves under the NBC management increased from merely 378 million US dollars from 15 years ago to over 4,100 million US dollars as of the date of the publication, able to cover more than 4 months of the country's import, reaching the height of wealth Cambodia as a nation has ever achieved.

In 2014 and going forward, the NBC will continue to implement its policies prudently in order to achieve its mission and contribute to the economic development and prosperity of the country.


Annual % Change of ASEAN Countries' Currencies
%
15
10
5
0
-5
-10
-15
-20
2004
2005
2006
2007
2008
2009
2010
2011
2012
2013
Cambodia Riels
Indonesia Rupiah
Malaysia Ringgit
Philippine Peso
Singapore Dollar
Thai Bath
Vietnamese Dong


Inflation of ASEAN Countries
%
25
20
15
10
5
0
Dec-10
Feb-11
Apr-11
Jun-11
Aug-11
Oct-11
Dec-11
Feb-12
Apr-12
Jun-12
Aug-12
Oct-12
Dec-12
Feb-13
Apr-13
Jun-13
Aug-13
Oct-13
Vietnam
Thailand
Cambodia
Singapore
Malaysia
Indonesia
Philippines